00755765

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 29 / 11 / 2011
ម៉ោង (Time/Heure) : 08 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E141/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ: ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ជូនចំពោះ:** **សហព្រះរាជអាជ្ញានៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង,ភាគីទាំងអស់នៃសំណុំរឿង ០០២ និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ការជូនដំណឹងជាមុនអំពីការចាត់តាំងភារកិច្ចក្នុងការសួរដេញដោលសាក្សីចំនួន៤រូប ក្នុងអំឡុងសវនាការជំណាក់កាលដំបូង(ពីថ្ងៃទី ០៥ ដល់ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១)**

ដូចដែលបានគូសបញ្ជាក់នៅក្នុងអនុស្សរណៈរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដែលបានផ្ញើទៅភាគីនោះ (ឯកសារ E141) តាមរយៈអនុស្សរណៈនេះ ប្រធានអង្គជំនុំជម្រះសាលា-ដំបូងអាចចាត់តាំងសហព្រះរាជអាជ្ញា ក្រុមមេធាវីការពារក្តីនីមួយៗ ឬសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនូវភារកិច្ចក្នុងការសួរដេញដោលសាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់នៅពេលសវនាការ។ ថ្វីបើប្រធានអង្គជំនុំជម្រះជាអ្នកចាប់ផ្តើមសួរសំណួរ និងលើកឡើងអំពីបញ្ហាបឋមនានាក្តី ក៏ការសួរសំណួរគឺជាបន្ទុករបស់ភាគីពាក់ព័ន្ធ។

តាមរយៈអនុស្សរណៈនេះ អង្គជំនុំជម្រះសាលាដំបូងចាត់តាំងសហព្រះរាជអាជ្ញាឲ្យទទួលខុសត្រូវចម្បងលើការសួរដេញដោលសាក្សីចំនួន៤រូបដូចមានបង្ហាញអត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ខ សម្ងាត់ (ឯកសារ E131/1.2) ដែលត្រូវស្តាប់សក្ខីកម្មក្នុងអំឡុងសវនាការជំណាក់កាលដំបូងនេះ។ សាក្សីទាំង៤

00755766

E14.1/2

រូបនេះមានអត្តលេខសម្គាល់ TCW 564, TCW 583, TCW 542 និង TCW 395។ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ សាក្សីទាំង៤រូបនឹងត្រូវអង្គជំនុំជម្រះស្តាប់សក្ខីកម្មតាមលំដាប់លំដោយដូចមានរៀបរាប់នៅក្នុងអនុស្សរណៈនេះ។

អង្គជំនុំជម្រះសូមរំឭកសហព្រះរាជអាជ្ញាថាខ្លួនត្រូវកំហិតការសួរដេញដោលត្រឹមអង្គហេតុពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងនេះតែប៉ុណ្ណោះ។ ប្រសិនបើខ្លួនយល់ថាសាក្សីទាំងនេះគួរផ្តល់សក្ខីកម្មលើអង្គហេតុផ្សេងៗដែលពុំស្ថិតក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ សហព្រះរាជអាជ្ញាអាចស្នើសុំដោយផ្ទាល់មាត់ទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីសម្រេចថាតើការស្តាប់សក្ខីកម្មសាក្សីទាំងនេះពាក់ព័ន្ធនឹងចំណុចអង្គហេតុដទៃទៀត មានប្រយោជន៍ធ្វើឱ្យការរៀបចំសវនាការទទួលបានប្រសិទ្ធភាពដែរឬទេ។ ថ្វីបើដូច្នេះ អង្គជំនុំជម្រះសូមបញ្ជាក់ថាការស្នើសុំបែបនេះពុំងាយទទួលបានការឯកភាពឡើយ។

សហព្រះរាជអាជ្ញាគួរគប្បីត្រៀមសំណួរសម្រាប់សាក្សីទាំង៤រូបនេះឱ្យបានរួចរាល់ត្រឹមថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១១។ អង្គជំនុំជម្រះនឹងងាកទៅស្តាប់សក្ខីកម្មសាក្សីដូចមានបង្ហាញអត្តសញ្ញាណនៅក្នុងឯកសារ E131/1.2 បន្ទាប់ពីបញ្ចប់ការសួរសំណួរទៅជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣ រូប ដូចមានបង្ហាញអត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធនេះ។ កាលបរិច្ឆេទខាងលើគ្រាន់ជាការស្នើតែប៉ុណ្ណោះ។